# J

Juvenile: **នៃយុវភាព មិនទាន់ពេញវ័យ (ខ្ចី)**

ដំណាក់កាលនៅក្មេង ឬមិនទាន់ពេញវ័យរបស់ដើមឈើមួយ ក្រុមពូជ ឬកូនឈើបណ្ដុះមួយ។ ពាក្យន័យផ្ទុយ ពេញវ័យ(mature)។ ដំណាក់កាលខ្ចីរបស់ដើមឈើ ជារឿយៗសំដៅទៅលើដំណាក់កាលមុនចេញផ្កា។ គេក៏ប្រើពាក្យនេះនៅក្នុងបរិបទរូបសាស្ត្រផងដែរ ដូចជាស្លឹកខ្ចី (juvenile leaves)។

មើល Cyclophysis, Hedging, Juvenile selection, Juvenile-mature correlation, Mature, Orthotopic growth, Rejuvenation, Plagiotropic growth, Topophysis.

Juvenile-mature correlation: **ទំនាក់ទំនងនៃយុវភាព (ភាពខ្ចី)និងពេញវ័យ**

ទំនាក់ទំនងខាងជីននេទិក ឬហ្វីណឺថៃបនៃបណ្ដាលក្ខណៈដែលគេវាយតំលៃនៅដំណាក់ខ្ចី ជាមួយលក្ខណៈទាំងនោះដែលសំដែងនៅអាយុពេញវ័យ។ សំដែងចេញមកជាមេគុណទំនាក់ទំនងរវាងទិន្នន័យគូៗដែលវាស់នៅអាយុផ្សេងៗគ្នា។

មើល Character, Correlation, Correlated response, Genetic correlation, Juvenile, Mature.

Juvenile selection: **ការជ្រើសរើសយុវភាព (ភាពនៅខ្ចី)**

ការជ្រើសរើសពីព្រៃពូជមិនទាន់ពេញវ័យដើម្បីកាត់បន្ថយចន្លោះពេលរបស់ជំនាន់។ ការជ្រើសរើសយុវភាពនេះ គេអាចកំណត់បាន បើសិនមានទំនាក់ទំនងយុវភាព-ពេញវ័យខ្ពស់មួយ។

មើល Advanced generation selection, Juvenile, Juvenile-mature correlation, Regression system